# ព្រឹត្តិបត្រអង្គការស្ត្រីខ្មែរកម្ពុជាក្រោម

## Khmer Kampuchea Krom Women Organization Bulletin

ចេញផ្សាយប្រចាំឆ្នាំមាស ឆ្នាំទី២ លេខ២៩ ពីថ្ងៃទី០១-១៥ ខែតុលា ឆ្នាំ២០០៩


## ទុក្ខលំបាកខ្មែរកម្ពុជាក្រោម

## ត្រូវបានលាតត្រដាង នៅក្នុងអង្គប្រជុំរដ្ឋសភាជាតិ នៃព្រះរាជាណាចក្រក

កាលពីថ្ងៃពុធ ទី២១ ខែតុលា ឆ្នាំ២០០៩ ថ្មីៗនេះ ឯកឧត្តម យន្ត ថារូ អ្នកតំណាងរាស្ត្រមណ្ឌលបន្ទាយមានជ័ មានឈាមជ័រជាខ្មែរកម្ពុជាក្រោម បានមានសំនួរចំនួន០២ សួរទៅតំណាងរាជរដ្ឋាភិបាល ដែលអង្គសភាបានពិភា បញ្ហាច្បាប់បាតុកម្ម។ សំនួរទី១: តើច្បាប់បាតុកម្មនេះ ហេតុអ្វីពុំបានចែងអំពីការបង្ករបួសស្នាម ឬស្លាប់ដល់បាតុករ ដែ ឡើងដោយសមត្ថកិច្ច? និងសំនួរទី២: តើច្បាប់បាតុកម្មនេះ ហេតុអ្វីបានជាពុំចែងអំពីសមត្ថកិច្ចបង្ករបួសស្នាម ឬស្លា ព្រះសង្ឃ? ដោយឯកឧត្តមបានលើកជាឧទាហរណ៍អំពីករណីជាក់ស្តែងកន្លងមក ដើម្បីងាយស្រួលដល់ការឆ្លើយបំភ្ តំណាងរាជរដ្ឋាភិបាល។

ឯកឧត្តមបានលើកជាភស្តុតាង ដូចជាករណី ព្រះសង្ឃខ្មែរកម្ពុជាក្រោមបានដង្ហែញត្តិជូនទៅស្ថានទូតវៀត ប្រចាំនៅកម្ពុជា កាលពីថ្ងៃទី២៧ ខែកុម្ភះ ឆ្នាំ២០០៧ ដែលមានព្រះសង្ឃចំនួន៧០-៨០អង្គ ហើយខ្លឹមសារនៃញត្តិនោះ ឱ្យស្ថានទូតជួយផ្តល់ទៅរដ្ឋាភិបាលវៀតណាម ស្តីពីការទាមទារសិទ្ធិសេរីភាពលើការសិក្សាវៀនសូត្រ និងការគោរព សាសនា ដែលពុទ្ធានុញ្ញាតបុណ្យកឋិនទានមានរយៈពេល៣០ថ្ងៃ ប៉ុន្តែរដ្ឋាភិបាលវៀតណាមបានបង្ខំឱ្យធ្វើតែ១ថ្ងៃ ម្យ៉ា ទៀត មូលហេតុដែលព្រះសង្ឃទាំងអស់អង្គដង្ហែញត្តិទៅនោះ ពីព្រោះកន្លងមកព្រះសង្ឃខ្មែរកម្ពុជាក្រោម តែងតែផ្ញើ ទៅស្ថានទូតវៀតណាមដោយស្ងាត់ៗតាមរបៀបកិច្ចការរដ្ឋបាល កុំថាឡើយដល់ការឆ្លើយតប សូម្បីតែទទួល ក៏ស្ថានទូ ណាមប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ពុំដែលបានទទួលម្តងណាឡើយ។ ហើយក្នុងថ្ងៃនោះដែរ ព្រះអង្គ អ៊ាង សុខ ដែលបានចូលរួមដង្ហែញត្តិនៅមុខស្ថានទូតវៀតណាមនោះ បន្ទាប់ពីឆាន់ត្រង់រួច ព្រះអង្គក៏លាព្រះភិក្ខុសង្ឃទាំងអស់អ វត្តសាមគ្គីរង្សីត្រឡប់ទៅវត្តព្រះអង្គវិញ។



ពុទ្ធោ ! ស្រាប់តែព្រឹកឡើងថ្ងៃទី២៨ ខែឆ្នាំដដែ ទទួលពតិមានគួរឱ្យរន្ធត់គឺ ព្រះអង្គ អ៊ាង សុខធឿន ត្រូវបាន ដោយអារកនៅវត្តទ្រនុំជ្រើង ឃុំបឹងធំ ស្រុកអង្គស្នួល ខេត្តកណ្ និងយកទៅបញ្ចុះទាំងយប់ដោយតក់ក្រហល់។ ពេលនោះអ សមាគម និងព្រះសង្ឃខ្មែរកម្ពុជាក្រោម រួមទាំងអង្គការ ស៊ីវិលមួយចំនួនទៀតដូចជា អង្គការសិទ្ធិមនុស្សលីកាដូ អា ព្រមទាំងអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សប្រ នៅកម្ពុជា បានរួបរួមគ្នាទៅបង្សុកូល ដើម្បីឧទ្ទិសកុសលប្រគេនព្រះតេជគុណ អ៊ាង សុខធឿន នៅកន្លែងបញ្ចុះ។ ប៉ុន្តែត្រូវ បានអាជ្ញាធរដែនដីពីថ្នាក់មូលដ្ឋានរហូតដល់ខេត្តកណ្តាល បានរារាំងមិនអនុញ្ញាតឱ្យចូលទៅដល់ទីកន្លែងបញ្ចុះសពនោះទេ។ ម្យ៉ាងវិញទៀតព្រះអង្គ អ៊ាង សុខធឿន ជាព្រះសង្ឃព្រះពុទ្ធសាសនាខ្មែរ ត្រូវបានយកទៅបូជា មិនគប្បីយកទៅបញ្ចុះទេ វាផ្ទុយទៅនឹងពុទ្ធប្បញ្ញត្តិយ៉ាងខ្លាំង។ ឯកឧត្តម យន្ត ថារូ បានមានប្រសាសន៍បន្តទៀតថា ឆ្លងតាមព្រឹត្តិការណ៍ទាំងអស់ខាង លើនេះ ឯកឧត្តមមានការសោកស្តាយយ៉ាងខ្លាំង ដោយហេតុថាបងប្អូនជនរួមឈាមខ្មែរកម្ពុជាក្រោម គឺជាខ្មែរគួរអាណោស់តែ ត្រូវបានអាជ្ញាធរខ្មែរលើកស្ទួយ និងការពារ ព្រមទាំងយកចិត្តទុកដាក់ខ្ពស់។ ប៉ុន្តែផ្ទុយទៅវិញ ត្រូវបានរងគ្រោះដោយការធ្វើ បាបយ៉ាងធ្ងន់ធ្ងរជាទីបំផុត ដូច្នេះសូមឱ្យឯកឧត្តមតំណាងរាជរដ្ឋាភិបាលមេត្តាពិចារណា និងគិតគូរឡើងវិញ។

ដោយឡែកការរំលឹកខួបលើកទី៦០ នៃទិវាបាត់បង់ទឹកដីកាលពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៩ កន្លងទៅថ្មីៗនេះ បង ប្អូនជនរួមឈាមខ្មែរកម្ពុជាក្រោម ទាំងព្រះសង្ឃ ទាំងគ្រហស្ថមានការឈឺចាប់យ៉ាងខ្លាំង ដោយក្រសួងមហាផ្ទៃបានអនុញ្ញាត ច្បាប់ឱ្យប្រារព្ធពិធីនៅសាលសន្និសីទចតុមុខ តាមការឯកភាពពីសាលារាជធានីភ្នំពេញ។ ប៉ុន្តែក្រសួងវប្បធម៌ និងវិចិត្រសិល្បះ មិនអនុញ្ញាតឱ្យទេ ថែមទាំងឱ្យរង់ចាំរហូតដល់ម៉ោង៥.៣០នាទីល្ងាច ស្រាប់តែអត់ចូលកន្លែង រួចឈានដល់ការបិទទូរស័ព្ទ តែម្តង។ បន្ទាប់មកគណៈកម្មការបុណ្យបានទៅអង្គុយចាំឯកឧត្តមរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បះនៅផ្ទះរបស់គាត់ តែម្តងរហូតដល់ម៉ោង៨.០០នាទីយប់ នៅតែពុំបានជួប។ ពេលនោះក៏សំរេចចិត្តផ្ញើឯកសារដែលក្រសួងមហាផ្ទៃបានអនុញ្ញាត នៅផ្ទះឯកឧត្តមរដ្ឋមន្ត្រី ប៉ុន្តែពេលឈានជើងផុតរបងផ្ទះ ស្រាប់តែមានទូរស័ព្ទប្រាប់អ្នកនៅផ្ទះឯកឧត្តមរដ្ឋមន្ត្រីក្រសួង វប្បធម៌ និងវិចិត្រសិល្បះកុំឱ្យទទួលឯកសារអ្វីទាំងអស់។ លុះបន្ទាប់មកទៀត គណៈកម្មការបុណ្យទាំងព្រះសង្ឃ ទាំងគ្រហស្ថ បានមកជួបជុំគ្នា ដោយមានសម្ភារៈ តុ កៅអី រោង វេទិកានៅមុខសាលសន្និសីទចតុមុខ រហូតដល់ម៉ោង១១.៣០នាទីយប់ នៅតែសន្តិសុខសាលសន្និសីទពុំបានបើកសោរឱ្យចូលដដែល។ ប៉ុន្តែក្នុងចន្លោះម៉ោង៩.០០នាទីយប់នោះ ឯកឧត្តម យន្ត ថារូ បានទូរស័ព្ទទៅឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃទាំងយប់ សុំឱ្យជួយធ្វើអន្តរាគមន៍ក្នុងករណី នេះផង។ ពីព្រោះថ្ងៃស្អែក ទី០៤ ខែមិថុនា ឆ្នាំ២០០៩ ពិធីបុណ្យរបស់បងប្អូនជនរួមឈាមខ្មែរកម្ពុជាក្រោម ដែលមានព្រះ រាជតំណាងដ៏ខ្ពង់ខ្ពស់ ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូងយាងចូលរួមទៀតផង យើងខ្ញុំមានការលំបាកយ៉ាងខ្លាំងក្នុង ការរៀបចំពិធី។ ដោយហេតុផលទាំងអស់ខាងលើ ពេលនោះឯកឧត្តមរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក៏បានជួយធ្វើអន្តរាគមន៍តាម សំណូមពរ។ លុះមកដល់ម៉ោង១២.០០នាទីយប់ ទើបសាលារាជធានីភ្នំពេញ បានកោះហៅគណៈកម្មការបុណ្យមកសម្រប សម្រួល ដើម្បីរៀបចំពិធីនៅសួនច្បារមុខវត្តមទុបវត្តិវិញ។ ទោះបីពេលវេលានៅសល់តែប៉ុន្មានម៉ោងទៀត ដល់ពេលប្រារព្ធ ពិធីក៏ដោយ ក៏ព្រះសង្ឃនិងបងប្អូនខ្មែរកម្ពុជាក្រោមបានសង់រោង និងវេទិកាទាំងយប់ដោយមានភ្លៀងទៀងផង ដើម្បីត្រៀម ទទួលព្រះរាជតំណាង និងភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ ព្រមទាំងព្រះសង្ឃរាប់ពាន់អង្គ នេះជាព្រឹត្តិការណ៍មួយ។ ដោយឡែក ព្រឹត្តិការណ៍មួយទៀត នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០០៨ សាលារាជធានីភ្នំពេញបានអនុញ្ញាតឱ្យបងប្អូនខ្មែរកម្ពុជាក្រោម ប្រារព្ធពិធីនៅទីស្នាក់ការរបស់ខ្លួនដែលមានផ្ទៃវែងទទឹង៤ម៉ែត្រ។ពេលនោះគណៈកម្មការបុណ្យបានសង់រោងតាមបណ្តោយ ផ្លូវនៅខាងមុខទីស្នាក់ការ ដោយទុកផ្លូវឱ្យរថយន្តទៅមកបាន ប៉ុន្តែស្រាប់តែក្រុមហ៊ុនឯកជនឱ្យរុះរោងចេញ ដោយគេប្រាប់ ថាផ្លូវនេះជាផ្លូវរបស់ក្រុមហ៊ុន ហើយពេលនោះទាំងពុទ្ធបរិស័ទ ទាំងព្រះសង្ឃ ឈរទាំងថ្ងៃក្តៅក្រោមព្រះរាជអធិបតីភាព ព្រះរាជតំណាងដ៏ឧដុង្គឧត្តម។ ដូច្នេះទុក្ខលំបាកខ្មែរកម្ពុជាក្រោម ត្រូវបានអាជ្ញាធរវៀតណាមធ្វើបាបម្តងហើយ លុះមក ដល់កម្ពុជាត្រូវបានអាជ្ញាធរ ខ្មែរកៀបសង្កត់ម្តងទៀត គឺជារឿងគួរឱ្យសោកស្តាយយ៉ាងក្រៃលែង។


អាសយដ្ឋាន: ផ្ទះលេខ១៩ ផ្លូវ២៩៤ ក្រុម៦៨ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ: ០១១ ៧១ ២៣ ២៥ / ០១១ ៦៣ ៦០ ១២

E-mail: kkkwo@yahoo.com



ចែកជូនដោយឥតគិតថ្លៃ

# ព្រឹត្តិបត្រអង្គការស្ត្រីខ្មែរកម្ពុជាក្រោម

## Khmer Kampuchea Krom Women Organization Bulletin

*ចេញផ្សាយប្រចាំអឌ្ឍមាស ឆ្នាំទី២ លេខ៣៣ ពីថ្ងៃទី១៦-៣១ ខែតុលា ឆ្នាំ២០០៩*

## ស្ថិតិប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម និងចម្ងាយផ្លូវ ក្នុងខេត្តនីមួយៗ នៅដែនដីកម្ពុជាក្រោម

| | | | |
|---|---|---|---|
| ១- | ពីទីក្រុងព្រៃនគរ ទៅខេត្តព្រះត្រពាំង | មានប្រវែង១៩០គីឡូម៉ែត្រ | និងមានចំនួនប្រជាជន២,៤៨០,០០០នាក់ |
| ២- | ពីទីក្រុងព្រៃនគរ ទៅខេត្តឃ្លាំង | មានប្រវែង២២០គីឡូម៉ែត្រ | និងមានចំនួនប្រជាជន២,៣២៥,០០០នាក់ |
| ៣- | ពីទីក្រុងព្រៃនគរ ទៅខេត្តមាត់ជ្រូក | មានប្រវែង២៥៤គីឡូម៉ែត្រ | និងមានចំនួនប្រជាជន២,១៧០,០០០នាក់ |
| ៤- | ពីទីក្រុងព្រៃនគរ ទៅខេត្តក្រមួនស | មានប្រវែង២១០គីឡូម៉ែត្រ | និងមានចំនួនប្រជាជន២,១៧០,០០០នាក់ |
| ៥- | ពីទីក្រុងព្រៃនគរ ទៅខេត្តពលលាវ | មានប្រវែង២៦០គីឡូម៉ែត្រ | និងមានចំនួនប្រជាជន៦២០,០០០នាក់ |
| ៦- | ពីទីក្រុងព្រៃនគរ ទៅខេត្តទឹកខ្មៅ | មានប្រវែង៣៤៧គីឡូម៉ែត្រ | និងមានចំនួនប្រជាជន៦២០,០០០នាក់ |
| ៧- | ពីទីក្រុងព្រៃនគរ ទៅខេត្តពាម | មានប្រវែង៣៣៨គីឡូម៉ែត្រ | និងមានចំនួនប្រជាជន៤៦៥,០០០នាក់ |
| ៨- | ពីទីក្រុងព្រៃនគរ ទៅខេត្តរោងដំរី | មានប្រវែង៩៩គីឡូម៉ែត្រ | និងមានចំនួនប្រជាជន៣១០,៧៧៥នាក់ |
| ៩- | ពីទីក្រុងព្រៃនគរ ទៅខេត្តព្រែកឫស្សី | មានប្រវែង១៦៨គីឡូម៉ែត្រ | និងមានចំនួនប្រជាជន៣១០,០០០នាក់ |
| ១០- | ពីទីក្រុងព្រៃនគរ ទៅខេត្តលង់ហោរ | មានប្រវែង១៣៦គីឡូម៉ែត្រ | និងមានចំនួនប្រជាជន៣១០,០០០នាក់ |
| ១១- | ពីទីក្រុងព្រៃនគរ ទៅខេត្តពាមបារ៉ាជ | មានប្រវែង១៩០គីឡូម៉ែត្រ | និងមានចំនួនប្រជាជន៣១០,០០០នាក់ |
| ១២- | ពីទីក្រុងភ្នំពេញ ទៅទីក្រុងព្រៃនគរ | មានប្រវែង២៤១គីឡូម៉ែត្រ | និងមានចំនួនប្រជាជន២៦៣,៥០០នាក់ |
| ១៣- | ពីទីក្រុងព្រៃនគរ ទៅខេត្តទួលតាមោក | មានប្រវែង៣០គីឡូម៉ែត្រ | និងមានចំនួនប្រជាជន៩៥,៣២៥នាក់ |
| ១៤- | ពីទីក្រុងព្រៃនគរ ទៅខេត្តផ្សារដែក | មានប្រវែង១៤៣គីឡូម៉ែត្រ | និងមានចំនួនប្រជាជន៣១,០០០នាក់ |
| ១៥- | ពីទីក្រុងព្រៃនគរ ទៅខេត្តកំពប់ស្រកាត្រី | មានប្រវែង៣០គីឡូម៉ែត្រ | និងមានចំនួនប្រជាជន១៨,៦០០នាក់ |
| ១៦- | ពីទីក្រុងព្រៃនគរ ទៅខេត្តព្រះសួគ៌ា | មានប្រវែង១០១គីឡូម៉ែត្រ | និងមានចំនួនប្រជាជន១០,៥៨០នាក់ |
| ១៧- | ពីទីក្រុងព្រៃនគរ ទៅខេត្តផ្សំអំបើស | មានប្រវែង៨៥គីឡូម៉ែត្រ | និងមានចំនួនប្រជាជន៩,៥២០នាក់ |
| ១៨- | ពីទីក្រុងព្រៃនគរ ទៅខេត្តមេ-ស | មានប្រវែង៧០គីឡូម៉ែត្រ | និងមានចំនួនប្រជាជន៩,៣០០នាក់ |
| ១៩- | ពីទីក្រុងព្រៃនគរ ទៅខេត្តកោះគង | មានប្រវែង៤៧គីឡូម៉ែត្រ | និងមានចំនួនប្រជាជន៩,៣០០នាក់ |
| ២០- | ពីទីក្រុងព្រៃនគរ ទៅខេត្តពេញ្ញាះថ្មី | មានប្រវែង៩២គីឡូម៉ែត្រ | និងមានចំនួនប្រជាជន៤,៦៥០នាក់ |
| ២១- | ពីទីក្រុងព្រៃនគរ ទៅខេត្តអូរកាប់ | មានប្រវែង១២៩គីឡូម៉ែត្រ | និងមានចំនួនប្រជាជន៤,០៣០នាក់ |

សរុបប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមមានចំនួន ១២,៩៤៧,២៥០ នាក់



# ពិធីបុណ្យកឋិនទាននៅកម្ពុជាក្រោម

នៅដែនដីកម្ពុជាក្រោម ការប្រារព្ធពិធីបុណ្យកឋិនទានមានរយៈពេល៣០ថ្ងៃ គឺចាប់ពីថ្ងៃពេញបូរមីខែអស្សុជ រហូតដល់ថ្ងៃពេញបូរមីខែកត្តិកជារៀងរាល់ឆ្នាំ ដូចនៅក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ។ ប៉ុន្តែមានការខុសគ្នាបន្តិចបន្តួច នៅលើការនិយមនៃការប្រារព្ធពិធីដូចជា នៅតាមគ្រួសារនីមួយៗ ក្រៅពីយកនំចំណីទៅវត្តរៀងៗខ្លួន នៅមានស្លាធម៌មួយដើមរំលេចដោយក្រដាសប្រាក់ ទៅតាមតិចនិងច្រើននៃសទ្ធារបស់ប្រជាពុទ្ធបរិស័ទ ហើយការប្រារព្ធបុណ្យកឋិនទានភាគច្រើនសុទ្ធតែបុណ្យកឋិនសាមគ្គី ពុំសូវមានកឋិនដង្ហែចូលពីខាងក្រៅទេ មានដែរ ប៉ុន្តែតិចតួចជាទីបំផុត។

ចំពោះឆ្នាំនេះមានបងប្អូនប្រជាពលរដ្ឋខ្មែរ ដែលមានដើមកំណើតកម្ពុជាក្រោមបានរួបរួមជាមួយនឹងព្រះសង្ឃ ប្រជាពុទ្ធបរិស័ទនៅភ្នំពេញ បានដង្ហែអង្គកឋិនទាន និងទៅទេសចរណ៍នៅដែនដីកម្ពុជាក្រោម យ៉ាងផុលផុសគួរឱ្យកត់សំគាល់។ ហេតុនេះក្នុងនាមព្រឹត្តិបត្រអង្គការស្ត្រីខ្មែរកម្ពុជាក្រោម សូមអំពាវនាវដល់ព្រះសង្ឃ ក៏ដូចជាបងប្អូនជនរួមឈាមខ្មែរទាំងអស់ព្រះមេត្តា និងមេត្តាជ្រាបថា ចាប់ពីពេលនេះតទៅ ប្រសិនបើមានសទ្ធាឬគោលបំណងដង្ហែអង្គកឋិនទាន ក៏ដូចជាបុណ្យផ្កាទៅកាន់ទឹកដីកម្ពុជាក្រោមទៀតនោះ។ សូមជួយជាវនូវសៀវភៅដែលជាក្បួនខ្នាតអក្សរសាស្ត្រខ្មែរ ទោះជាសៀវភៅធម៌ ឬសៀវភៅអប់រំសង្គមក៏ដោយ ជួយយកទៅចែកជូនដល់បងប្អូនប្រជាពលរដ្ឋខ្មែរនៅដែនដីកម្ពុជាក្រោមឱ្យបានច្រើន គឺជាការល្អជាទីបំផុត។ ពីព្រោះនៅទីនោះពុំមានរោងពុម្ពអក្សរសាស្ត្រខ្មែរទេ ហើយរាល់ការផលិតសៀវភៅជាអក្សរសាស្ត្រខ្មែរនោះ ត្រូវបានការស្រាវជ្រាវ និងតាមដាន ព្រមទាំងមានការចោទប្រកាន់ពីអាជ្ញាធរវៀតណាមគ្រប់ពេលវេលា។ ករណីទាំងអស់នេះបានធ្វើឱ្យព្រះសង្ឃ និងបងប្អូនជនរួមឈាមខ្មែរកម្ពុជាក្រោមភ័យខ្លាចពុំសូវហ៊ានផលិត ឬបោះពុម្ពសៀវភៅជាអក្សរសាស្ត្រខ្មែរឱ្យបានទូលំទូលាយ ដូចប្រជាពលរដ្ឋខ្មែរយើងនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាទេ។ ដូចជនរួមឈាមយើងយល់ស្រាប់ហើយថា ខ្មែរកម្ពុជាក្រោមរស់នៅក្រោមអាណានិគមនិយមវៀតណាម ចាប់តាំងពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៤៩មក ទុក្ខវេទនាមានច្រើនឥតគណនា ពុំដែលស្គាល់ទេនូវសិទ្ធិសេរីភាព ពុំដែលស្គាល់ទេនូវសិទ្ធិមនុស្ស ដូចមនុស្សជាតិទាំងឡាយនៅលើពិភពលោកយើងនេះ មានន័យថាពួកគាត់រស់នៅក្នុងគំនាបដ៏តានតឹងជាទីបំផុត គឺរស់ឱ្យតែបានរស់ រស់ដើម្បីរស់ ពុំមានអត្ថន័យទាំងអស់។





បងប្អូនខ្មែរកម្ពុជាក្រោម រៀបចំដង្ហែអង្គកឋិនទាន ឆ្ពោះទៅដែនដីកំណើត
ដែលជាទីស្រឡាញ់របស់ខ្លួន នៅឯកម្ពុជាក្រោម

រាល់ការជួយឧបត្ថម្ភបោះពុម្ពព្រឹត្តិបត្រ មេត្តាទាក់ទងលេខទូរស័ព្ទនៅទំព័រខាងលើ សូមអរគុណ